# ព្រះពុទ្ធរូបសម័យផ្សេង ៗ

កាលពីខែសេបតមប្រ៏ ឆ្នាំ ១៩៣៨ នៅស្រុកប្រ៊ុកសែល ជាទីក្រុងនៃប្រទេសបេស៊ិក ស្រុកនេះជាស្រុកតូចតាំងនៅខាងជើងស្រុកបារាំង ។ ស្រុកនេះហើយជាទីប្រជុំដ៏សំខាន់មួយ ដែលមានការមករួបរួមប្រជុំគ្នានៃបណ្តាបុគ្គលគ្រប់ ៗ ប្រទេសក្នុងលោក ដើម្បីពិគ្រោះការងារជាមួយគ្នាអំពីប្រស្នាផ្សេង ៗ ដែលទាក់ទងនឹងចំណែកទិសខាងកើត ។

មានអ្នកប្រាជ្ញបារាំងសែសម្នាក់ឈ្មោះលោក ហ្វីយេអូសាត៍ បានពោលថ្លៃងអំពីកិច្ចការរបស់អ្នកប្រាជ្ញ ១ រូបប៉ែកខាងព្រះពុទ្ធសាសនាលិទ្ធិមហាយានឈ្មោះលោក នាគាជុន៌ ជាអ្នកប្រាជ្ញល្បីល្បាញ លោកអ្នកប្រាជ្ញនេះបានតែងតម្រាពេទ្យសាស្ត្រនឹងតម្រាញែកជាតុ ផ្សំជាតុ ជាភាសាសំស្ក្រឹតដែលអាចនាំទៅប្រៀបផ្ទឹមនឹងអ្នកប្រាជ្ញ ១ រូបនៅខាងទក្សិណទិសនៃស្រុកឥណ្ឌៀ « អយស្រ្តៈ » ជាអ្នករៀបចំតែងគម្ពីរពេទ្យសាស្រ្ត នឹងគម្ពីរញែកជាតុផ្សំជាតុដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញក្នុងស្រុកសៀមនឹងស្រុកខ្មែរកាលពីជាន់ដើម ។

លោកអ្នកប្រាជ្ញទាំងពីររូបនេះបានតែងគម្ពីរ មានសេចក្តីជាគោលសំខាន់ ៗ ដូចគ្នាអំពីវិជ្ជាចិត្តសាស្រ្ត នៃប្រទេសឥណ្ឌៀហើយគម្ពីរទាំងពីរនេះមិនមានរឿងរ៉ាវខាងសាសនាលាយសោះឡើយ ។

មានជនជាតិអង់គ្លេសម្នាក់ឈ្មោះឡឺម៉ៃដែលធ្លាប់នៅស្រុកសៀមជាវេលាយូរ បាននិយាយអំពីពង្សាវតារនៅសម័យផ្សេង ៗ នៃស្រុកសៀមនេះដែលលោកឡឺម៉ៃបានឃើញគ្រឿងចម្លាក់រចនាផ្សេង ៗ ដែលមាននៅក្នុងស្រុក ហើយមានប្រយោជន៍ដល់អ្នកមើលរឿងនេះទូទៅក្នុងស្រុកខ្មែរ ។ ឯសេចក្តីទៅនេះជាសេចក្តីសង្ខេបខ្លី ៗ ទេ ។

១ សម័យមុនពុទ្ធសករាជ ៩៤៣ . ១៥៤៣ – បែបចំឡាក់រចនាជាន់បុរាណច្រើនជាងគេដែលមាននៅស្រុកសៀមនោះជាចំឡាក់បែបមន ។ ពួកមននេះមកអំពីប្រទេសភូមាក្រោម ( Basse Birmanie ) កំណើតដើមនៅមាត់សមុទ្រស្រុកឥណ្ឌៀខាងកើត ។ ក្បាច់រចនារបស់មននេះសុទ្ធតែមានគិនភាគបែបឥណ្ឌូ តាំងអំពីសម័យនៃពុទ្ធសករាជ ៨៤៣ ដល់ ៩៤៣ ក្រោយមកទើបគេស្គាល់ព្រះនាមនៃវង្សស្តេចមននេះ តាំងអំពីកាលនៅស្រុកឥណ្ឌៀ គឺក្នុងសម័យ « ក្សត្រ គុប្តៈ » នៅប្រទេសប៉ែកខាងជើង ។

១ សម័យខ្មែរ ពុទ្ធសករាជ ១៥៤៣ ដល់ពុទ្ធសករាជ ១៧៩៣ – តាំងអំពីពុទ្ធសករាជ ១២៤៣ មកពួកខ្មែរបានវាតឫទ្ធិអំណាចឲ្យរីកចេញទៅ ក្រោយដែលបានតាំងក្រុងនៅទីក្រុងអង្គរ ប្រទេស

កម្ពុជា ។ កាលក្នុងពុទ្ធសករាជ ១៥៤៣ ស្រុកសៀមកណ្តាលនៅក្នុងអំណាចមហាអាណាចក្រខ្មែរនៅឡើយ ។ មានឧបរាជមួយអង្គគង់នៅក្រុងលពបូរីជាទីប្រជុំជាន់បុរាណប្រកាន់តាមអារ្យធម៌របស់មន ក្រុងលុពបូរីនេះនៅជាខាងជើងក្រុងបាងកកចម្ងាយ ៨០ មីល ( 80 miles ខ្នាតរបស់អង់គ្លេសមួយយ៉ាង អានថាម៉ៃក្នុង ១ ម៉ៃប្រហែល ១.៥០០ ម៉ែត្រ ) ។ នៅទីនោះមានសាលាបង្រៀនចម្លាក់បែបខ្មែរ ១ យ៉ាង ប៉ុន្តែមានបែបភាពប្លែកភាពប្លែកផ្សេងពីក្បាច់ចំឡាក់ដែលមាននៅក្នុងស្រុកខ្មែរ ។

បែបភាពព្រះពុទ្ធរូបខ្មែរមានទ្រង់ទ្រាយជាភេទបុរស ឃើញស្តែងជាងព្រះពុទ្ធរូបដែលធ្វើដោយស្នាដៃមន ។ ពួកខ្មែរច្រើនប្រើដីពេជ្រនឹងសំរិទ្ធិសាងព្រះ ប៉ុន្តែរូបធ្វើពីសំរិទ្ធិធ្លាប់មានតែព្រះអង្គតូច ៗ ហើយដំកល់ទុកបូជានៅផ្ទះ ។

៣ – សម័យធៀងសែន ព. ស. ១. ៦៤៣ ដល់ ១.៧៤៣ – តាំងអំពីពុទ្ធសករាជ ១៣៩៣ នោះពួកថៃ ( សៀម ) មានលំនៅដើម ( ស្រុកកំណើត ) នៅស្រុកចិនខាងត្បូង ហើយមកតាំងស្រុកទេសថ្មីនៅស្រុកលាវ – សៀម ខាងជើង កាលពី ព. ស. ១.៦០០ នោះមហាក្សត្រជាតិភូមា ព្រះនាមអនុរុទ្ធមហារាជទី ១ ទ្រង់មានស្ពានមេត្រីនឹងស្តេចព្រះនាមបលៈ ស្រុកឥណ្ឌៀនៅខេត្រពិហារ ក្សត្រភូមាអង្គនេះទ្រង់បានព្រះពុទ្ធរូបបែបថ្មី ១ អង្គ នាំមកដំកល់ទុកនៅប្រទេសភូមា ហើយវេលានោះនៅខាងជើងស្រុកសៀម ក្នុងតំបន់ដែនធៀងសែននោះ មានរូបសំរិទ្ធិជាចំនួនច្រើនដែលគេបានកសាងឡើងក្នុងសម័យនោះ ។

៤ – សម័យសុខោទ័យប្រហែលពី ព. ស. ១. ៧៤៣ ដល់ ១.៨៤៣ – គឺកាលពី ព. ស. ១.៧៩៣ ដែលពួកថៃ ( សៀម ) តាំងប្រទេសអាណាចក្រនៅស្រុកហៅថា សុខោទ័យ នឹងសួគ៌ាលោក ( សៀមអានថាស្វ័នខះលោក ) មួយទៀត ទុកដូចជាទីក្រុងដែរ ។ ឯបែបសិល្បកម្មក្នុងសម័យនោះ បានទទួលបែបភាពថ្មីដែលបានពីកោះលង្កា ហើយបែបផែនព្រះពុទ្ធរូបថ្មីនេះក្លាយទៅជាបែបសិល្បកម្មយ៉ាងវិចិត្រជារបស់សៀមដែលប្លែកយ៉ាងស្រឡះពីបែបខ្មែរដោយមានរង្វង់ព្រះភក្ត្រទម្រង់ពងក្រពើមានព្រះភូមោ ( ចិញ្ចើម ) កោងដូចជាវង់ធ្នូ ហើយមានព្រះអាការជាគ្រឿងសំដែងភាពបែបផែនព្រះពុទ្ធរូប ។

អស់ពួកលោកដែរដើរប្រកាសសាសនា បានដើរផ្សាយបែបសិល្បកម្មពុទ្ធសាសនាថ្មីនេះចូលទៅស្រុកសៀម តាំងអំពីខាងជើងទៅខាងត្បូង ។

៥ – សម័យអ៊ូថង អំណាចខ្មែរនឹងសៀម ប្រហែលជាក្នុង ព. ស. ១.៧៤៣ ដល់ ១.៨៤៣ – ក្នុងចំណោក

ដែនលុពបុរី មានពេលខ្លះគង់ទ្រង់នៅមិនធ្លាក់នៅក្នុងអំណាចស្រុកសុខោទ័យ ហើយក្នុងសម័យនោះ ទុកដូចជាឈ្មោះក្រុង ១ ដែលនៅខាងលិចស្រុកអយុទ្យា ។ បណ្តារូបដែលធ្វើពីសំរិទ្ធិក៏ផ្តើមកើតមានឡើងតាមបែបផែនខ្មែរ ច្រើនជាងបែបជារបស់សៀមប៉ុន្តែតបន្តិច ៗ មក គេក៏កែប្រែទៅតាមគំនិតយោបល់ជាបែបសៀមវិញ ។

៦ – សម័យសៀមអយុទ្យាពី ព. ស. ១.៦៩៣ ប្រហែលដល់ទៅ ព. ស. ២.១៤៣ ដល់ ១.៨៩៣ ក្សត្រនៃស្រុកអ៊ូថងបានកតាំងទីក្រុងថ្មីនៅស្រុកអយុទ្យា ហើយភ្ជាប់ទាំងស្រុកសុខោទ័យ ( មកជាចំណុះផង ) ។ ការចំឡាក់លើផ្ទាំងថ្មនៅស្រុកលុពបូរីក៏នៅមាននៅឡើយ ប៉ុន្តែបែបរចនាយ៉ាងល្អ ៗ ជាច្រើនអំពីដើមរលត់រលាយទៅក៏ពិតមែន តែបានឲ្យកំណើតដល់បែបសិល្បកម្មទំនើបថ្មីជារបស់សម្រាប់ជាតិ ដោយបង្កើតសាលាបង្រៀនដែលឈ្មោះថាសាលាអយុទ្យាឡើង ។

អំណាចបែបផែនខ្មែរនៅមានជាប់ជិតនៅនឹងគ្រឿងលំអរនៃគ្រឿងកសាងនឹងរូបផ្សេង ៗ ខ្លះ ហើយមានរូបសំរិទ្ធិជាច្រើននឹងរូបធ្វើពីឈើក៏មានច្រើនដែរ ។

លោកការិតវ៉ាល់ ដែលជាអ្នកគាស់កកាយរុករកក្នុងស្រុកម៉ាឡាយូ បានផ្ញើសេចក្តីរាយការណ៍មួយទៅជូនក្រុមជំនុំនានាជាតិចំណែកចុងបូព៌ាប្រទេសពិនិត្យមើល នោះមានសេចក្តីថា គេបានរកឃើញរឿងរ៉ាវខាងពុទ្ធសាសនាដែលឆ្លាក់ទុកនៅនឹងសិលាចារិកជាន់ចាស់ នឹងបល្ល័ង្កព្រះដែលគេខំពិនិត្យមើលនៅវេលានេះ នៅត្រង់កន្លែងនេះដើម្បីឲ្យបានដឹងថា បណ្តាបោរាណវត្ថុផ្សេង ៗ ( ដែលជាសម្បត្តិពុទ្ធសាសនា ) ដែលគេបានរកឃើញតើនៅក្នុងសម័យណា ។